**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# សាររំលែកមរណទុក្ខ

**សូមគោរពជូន**
**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ចំពោះមរណភាព ឯកឧត្តម ហ៊ុន ណេង សមាជិកអចិន្ត្រៃយ៍រដ្ឋសភា និងជាអ្នកតំណាងរាស្ត្រមណ្ឌលខេត្តកំពង់ចាម**

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!

យើងខ្ញុំជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ មានសេចក្ដីរន្ធត់ តក់ស្លុតឥតឧបមា និងក្ដុកក្ដួលរំជួលចិត្ត សោកស្ដាយជាពន់ពេកក្រោយពីបានទទួលដំណឹងថា **ឯកឧត្តម ហ៊ុន ណេង** សមាជិកអចិន្ត្រៃយ៍រដ្ឋសភា និងជាអ្នកតំណាងរាស្ត្រមណ្ឌលខេត្តកំពង់ចាម បានទទួលមរណភាពកាលពីថ្ងៃព្រហស្បតិ៍ ៥កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៥ ត្រូវនឹងថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង ០៦:២៥ នាទីល្ងាច ក្នុងជន្មាយុ ៧២ឆ្នាំ ដោយរោគាពាធ។

ក្នុងវេលាពោរពេញដោយក្ដីរំជួលចិត្តចំពោះមរណទុក្ខដ៏ក្រៀមក្រំបំផុតនេះ យើងខ្ញុំជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ សូមសម្ដែងនូវសេចក្ដីសោកស្ដាយស្រណោះ អាឡោះអាល័យរកទីបំផុតគ្មាន ជាមួយ **សម្ដេចតេជោ និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ព្រមទាំងក្រុមគ្រួសារ** ចំពោះមរណភាពរបស់ **ឯកឧត្តម ហ៊ុន ណេង** ដែលជាការបាត់បង់នូវបង បងថ្លៃ ឪពុកធំ និងជីតាជាទីស្រឡាញ់ដ៏ឧត្ដុង្គឧត្ដម ប្រកបដោយព្រហ្មវិហារធម៌។ មរណភាពរបស់ **ឯកឧត្តម ហ៊ុន ណេង** គឺជាការបាត់បង់យ៉ាងធំធេងនូវឥស្សរជនជាន់ខ្ពស់មួយរូប ដែលមួយជីវិតរបស់ **ឯកឧត្តម** បានបូជាទាំងកម្លាំងកាយនិងចិត្ត ប្រាជ្ញា ស្មារតី ក្នុងការបម្រើជាតិ សាសនា ព្រះមហាក្សត្រ និងប្រជាជនកម្ពុជា យ៉ាងបូរផ្ដាច់បំផុត។

ស្ថិតក្នុងបរិយាកាសដ៏មហាក្រៀមក្រំបំផុតនេះ យើងខ្ញុំទាំងអស់គ្នា សូមឧទ្ទិសបួងសួងជូនវិញ្ញាណក្ខន្ធរបស់ **ឯកឧត្តម ហ៊ុន ណេង** សូមបានអញ្ជើញទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្ដេចតេជោ នាយករដ្ឋមន្ត្រី និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ព្រមទាំងក្រុមគ្រួសារ** មេត្តាទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីយើងខ្ញុំ៕

ថ្ងៃ ព្រហស្បតិ៍ ៥កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ២០២២
**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការក្រសួងមុខងារសាធារណៈ**
រដ្ឋមន្ត្រី

**ញ៉ឹម-សុខា**